UNITED NATIONS
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR

# សេចក្តីថ្លែងការណ៍ របស់លោកតំណាងពិសេស របស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំកម្ពុជា ស្តីពីការបណ្តេញចេញដោយបង្ខំ នូវជនជាតិរស់នៅតាមតំបន់ព្រៃភ្នំ ដែលជាអ្នកស្វែងរកសិទ្ធិជ្រកកោណ

## ថ្ងៃទី ៤ ខែមីនា ឆ្នាំ ២០០២

លោកតំណាងពិសេសមានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការបណ្តេញចេញដោយបង្ខំនៃជនជាតិភាគតិចរស់នៅតាមដំបន់ព្រៃភ្នំ ទៅកាន់ប្រទេសវៀតណាមវិញ កាលពីថ្ងៃទី ២ ខែមីនា ឆ្នាំ ២០០២ កន្លងទៅនេះ ។

មនុស្សទាំងនេះត្រូវបណ្តេញចេញ ដោយប្រឆាំងទៅលើការជំទាស់របស់បុគ្គលិក នៃស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិសំរាប់ជនភៀសខ្លួន ។ ពួកគេបានឆ្លងកាត់ព្រំដែនវៀតណាម មកកាន់ស្រុកអណ្តូងមាស ខេត្តរតនៈគីរី យ៉ាងតិចណាស់មួយថ្ងៃមុន ប៉ុន្តែនគរបាលខេត្តបានបដិសេធមិនឱ្យមន្ត្រីអង្គការសហប្រជាជាតិចូលទៅជួបពួកគេ ដោយយកលេសថាពួកជនជាតិរស់នៅតាមព្រៃភ្នំទាំងនេះ គឺជា "ជនអន្តោប្រវេសន៍ខុសច្បាប់" ។

ការបណ្តេញចេញទាំងនេះ គឺជាការរំលោភយ៉ាងច្បាស់ទៅលើអនុសញ្ញា ឆ្នាំ ១៩៥១ ស្តីពីជនភៀសខ្លួន ដែលប្រទេសកម្ពុជាជាភាគីមួយដែរ ។ គោលការណ៍មិនបណ្តេញចេញនៅក្នុងអនុសញ្ញានេះ បានចែងថា អ្នកស្វែងរកសិទ្ធិជ្រកកោណមិនត្រូវវិលត្រឡប់ទៅកាន់ប្រទេសមួយ ដែលខ្លួនអាចប្រឈមមុខនឹងការភ័យខ្លាចដោយមានហេតុផលច្បាស់លាស់ នៃការធ្វើទុក្ខបុកម្នេញឡើយ ។

#16A, Mao Tse Tuong Blvd, Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១៦A មហាវិថី ម៉ៅ សេទុង សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧

នេះមិនមែនជាលើកទី ១ ទេ ដែលឧប្បត្តិហេតុបែបនេះ ដែលលោកតំណាងពិសេសបានដឹង ។ នៅក្នុងរបាយការណ៍ ចុះថ្ងៃទី ២១ ខែកក្កដា ឆ្នាំ ២០០១ របស់លោក ទៅកាន់មហាសន្និបាតអង្គការសហប្រជាជាតិ លោកតំណាងពិសេសបានសំដែងសេចក្តីព្រួយបារម្ភថា ជនជាតិនៅតាមតំបន់ព្រៃភ្នំ បានត្រូវធ្វើមាតុភូមិនិវត្តន៍ ដោយមិនបានពិនិត្យឱ្យបានត្រឹមត្រូវនូវការសុំសិទ្ធិជ្រកកោណរបស់ពួកគេទេ ។ នៅពេលនោះ លោកបានសំដែងសេចក្តីសង្ឃឹមថា ប្រទេសកម្ពុជានឹងអនុវត្តន៍តាមកាតព្វកិច្ចរបស់ខ្លួនស្របតាមអនុសញ្ញាស្តីពីជនភៀសខ្លួន ឆ្នាំ ១៩៥១ ជាមិនខាន ។ លោកតំណាងពិសេស មានសេចក្តីសោកស្តាយដោយសារថាការណ៍នេះហាក់ដូចជាមិនត្រូវបានធ្វើទៅតាមការដែលបានគិតទុកនេះទេវិញ ។

នៅថ្ងៃទី ២៥ ខែមករា កន្លងទៅនេះ ប្រទេសវៀតណាមបានកាត់ទោស និងផ្តន្ទាទោស ជនជាតិរស់នៅតាមតំបន់ព្រៃភ្នំដែលជាអ្នកសុំសិទ្ធិជ្រកកោណ ចំនួន ៤ នាក់ ដែលត្រូវបណ្តេញចេញដោយបង្ខំពីប្រទេសកម្ពុជា ។ មនុស្សទាំងនេះត្រូវបានកាត់ទោសឱ្យជាប់គុក រហូតដល់ ៦ ឆ្នាំ កន្លះ ពីបទ "រៀបចំការផ្លាស់ប្តូរទីលំនៅដោយខុសច្បាប់" ។ មានសេចក្តីព្រួយបារម្ភមិនតិចជាងនេះទេ គឺការជាក់ស្តែងដែលថាមានប្រព្រឹត្តកម្មមិនសមរម្យពីសំណាក់អាជ្ញាធរកម្ពុជា ។ នៅក្នុងពេលទស្សនៈកិច្ចរបស់មន្ត្រីវៀតណាម និងកម្ពុជា កាលពីថ្ងៃទី ២២ ខែកុម្ភៈ ទៅកាន់ជំរុំមួយរបស់អគ្គស្នងការអង្គការសហប្រជាជាតិសំរាប់ជនភៀសខ្លួន អ្នកស្វែងរកសិទ្ធិជ្រកកោណចំនួន ៥ នាក់ ត្រូវបានវាយនឹងដំបងខ្សែភ្លើង ក្រោយពេលពួកគេនិយាយប្រឆាំងការធ្វើមាតុភូមិនិវត្តន៍ ។

នេះគឺជាការទទួលខុសត្រូវរបស់អាជ្ញាធរកម្ពុជា ក្នុងការធានាថាពួកអ្នកទទួលខុសត្រូវចំពោះឧប្បត្តិហេតុនេះ ត្រូវតែចាប់ឱ្យទទួលខុសត្រូវ និងធានាថាបុគ្គលិករបស់ស្នងការជាន់របស់អង្គការសហប្រជាជាតិសំរាប់ជនភៀសខ្លួន ត្រូវបានអនុញ្ញាតឱ្យបំពេញកាងាររបស់ពួកគេបានដោយសមស្រប ។ ការធ្វើមាតុភូមិនិវត្តន៍ ត្រូវតែប្រព្រឹត្តទៅដោយស្ម័គ្រចិត្ត ។ ពុំមានអ្នកសុំសិទ្ធិជ្រនកោណណាម្នាក់ ត្រូវទទួលរងនូវប្រព្រឹត្តកម្មមិនសមរម្យ និងណ្តេញចេញដោយបង្ខំ ទេ ។ ចំពោះករណីទាំងនេះ និងចំពោះទិដ្ឋភាពទាំងអស់ លោកតំណាងពិសេស សូមអំពាវនាវដលរាជរដ្ឋាភិបាលកម្ពុជា សូមបំពេញដោយពេញលេញ នូវកាតព្វកិច្ច អន្តរជាតិរបស់ខ្លួន ស្តីពីការថែទាំជនភៀសខ្លួន ។